**San Diego Unified School District**
EUGENE BRUCKER EDUCATION CENTER
4100 Normal Street, San Diego, CA 92103-2682
(619) 725-5506

**Carl A. Cohn**
អគ្គស្នងការក្រសួងអប់រំប្រចាំក្រុង

ខែ ឧសភា ឆ្នាំ ២០០៧

មាតាបិតា និងអ្នកអាណាព្យាបាលសិស្សជាទីរាប់អាន,

គួរអោយអស្ចារ្យណាស់! សិស្សដែលបានចុះឈ្មោះចូលរៀនទៅក្នុងក្រសួងអប់រំប្រចាំក្រុងរបស់យើងនារដូវស្លឹកឈើលាស់នេះនឹងរៀនចប់ទទួលសញ្ញាប័ត្រពីសាលាវិទ្យាល័យនាឆ្នាំ ២០២០។ ពេលនេះមាតាបិតាសិស្សសាលាមត្តេយ្យដ្ឋានមានសេចក្តីរីករាយចំពោះកូនរបស់ខ្លួនដែលមានអាយុប្រាំឆ្នាំនឹងចូលរៀនទៅតាមសាលារៀនរបស់យើងនារដូវស្លឹកឈើធ្លាក់ខាងមុខនេះ។ មាតាបិតាសិស្សទាំងនេះមានសេចក្តីសង្ឃឹមខ្លាំងមាំ ព្រមទាំងមានការសេចក្តីទុកចិត្តទៅកូនរបស់ខ្លួនសិក្សាផងដែរ។ មាតាបិតាគួរតែមានសេចក្តីទុកចិត្តទៅលើសមាជិកគ្រួសាររបស់ខ្លួនចូលរៀនទៅតាមសាលារៀនរបស់យើងដែលផ្តល់ការ បង្រៀនអប់រំ, រៀបចំបន្តការសិក្សាទៅតាមសាលាមហាវិទ្យាល័យ, រៀនមុខវិជ្ជាជីវៈ, មានអនាគតភ្លឺថ្លា ព្រមទាំងមានជីវិតថ្លៃថ្នូរទៀតផង។ មាតាបិតាយល់ដឹងថា ការសិក្សាអប់រំមានសារៈសំខាន់ជាទីបំផុតដែលអាចធ្វើអោយកូនរបស់គាត់សម្រេចតាមការសុបិនដែលកើតមានឡើងចំពោះកូនរបស់គាត់យ៉ាងជាក់លាក់។

មាតាបិតា ព្រមទាំងលោកគ្រូ-អ្នកគ្រូយកចិត្តទុកដាក់ទៅលើការសិក្សាជារៀងរាល់ថ្ងៃ។សិស្សចូលរៀនពីថ្នាក់មត្តេយ្យដ្ឋានដល់ថ្នាក់ទីដប់ពីរមានចំនួន ២៣៤០ថ្ងៃ ហេតុដូច្នេះការមករៀនជារៀនរាល់ថ្ងៃមានការឆាប់រហ័សជាទីបំផុតចាប់ពីថ្ងៃចូលរៀនរហូតដល់ថ្ងៃទទួលសញ្ញាប័ត្រពីសាលាវិទ្យាល័យ។ ក្នុងរយះពេលសិក្សាចំនួន ១៣ឆ្នាំ ការសិក្សារបស់សិស្សអាចធ្វើអោយសិស្សទទួលជំនាញការសិក្សា ព្រមទាំងមានឱកាសសិក្សា ព្រមទាំងទទួលការយល់ដឹងអំពីជីវិត។ ខ្ញុំសង្ឃឹមថា លោកអ្នកអាចយល់អំពីការណែនាំកូនចៅដោយចូលរួមជាមួយកម្មវិធីសាលារៀន និងការសិក្សារបស់សិស្ស ព្រមទាំងចូលរួមជាសកម្មជាមួយកម្មវិធីសិក្សារបស់កូនបានយ៉ាងល្អប្រសើរ។

លោកគ្រូ-អ្នកគ្រូ ព្រមទាំងបុគ្គលិកសាលារៀនរបស់យើងនឹងខិតខំយ៉ាងខ្លាំងក្លានាឆ្នាំនេះ ដើម្បីណែនាំសិស្សសិក្សា ។ យើងមានបំណងចង់ជួយដល់សិស្សរបស់យើងគ្រប់រូបមិនត្រឹមតែមានជំនាញការសិក្សាប៉ុណ្ណោះនោះទេ យើងនឹងណែនាំសិស្សទទួលផលប្រយោជន៍ពីការបង្រៀនដើម្បីពង្រឹងកការសិក្សាអោយបានល្អលាស់។

ពេលនេះ យើងកំពុងតែស្ថិតចូលដល់ខែ មិថុនា យើងសូមថ្លែងអំណរគុណដល់លោកអ្នកដែលជាមាតាបិតាសិស្សដែលបានជួយ ព្រមទាំងចូលរួមជាសកម្មជាមួយសាលារៀនយើង។ ការគាំទ្ររបស់លោកអ្នកនៅតាមផ្ទះអាចធ្វើអោយសិស្សទទួលការរីកចំរើនយ៉ាងខ្លាំងក្លាទៅតាមសាលារៀន។ ពេលនេះ សិស្សត្រូវតែចំណាយពេលវេលា និងមានការប្រុងប្រយ័ត្នស្តាប់លោកគ្រូ-អ្នកគ្រូធ្វើការបង្រៀន; ប្រុងប្រៀបខ្លួនចូលរួមប្រឡងវិញ្ញាសារ, គេងអោយបានគ្រប់គ្រាន់, កំណត់ពេលវេលាមើលទូរទស្សន៍, ប្រើប្រាស់ web និងលេងវីឌីអូ games ព្រមទាំងធ្វើកិច្ចការដែលគ្រូដាក់អោយធ្វើនៅតាមផ្ទះបានចប់សព្វគ្រប់។ ការខិតខំព្យាយាមនេះអាចធ្វើអោយសិស្សទទួលផលប្រយោជន៍ក្នុងការសិក្សាបានសម្រេចដូចបំណងដូចជា: បានទទួលពិន្ទុល្អ ព្រមទាំងសិស្សអាចទទួលសម្រេចកិច្ចការបានយ៉ាងច្រើនទៀតផង។

ខ្ញុំសូមលើកទឹកចិត្តលោកអ្នកណែនាំកូនឆក់យកឱកាសដ៏មានតម្លៃដែលយើងផ្តល់ដល់សិស្សសិក្សាទៅតាមសាលារៀនជារៀងរាល់ថ្ងៃនេះ។ ចូររួមសហការណ៍! សូមអញ្ជើញចូលរួម! សូមសិក្សាអោយបានច្រើន! យើងមានបំណងចង់អោយសិស្សគ្រប់រូបដែលជាសមាជិកគ្រួសាររបស់សាលារៀនយើងផ្ទាល់ទទួលការការសិក្សាបានល្អប្រសើរ។ សូមអរគុណលោកអ្នកជាខ្លាំងដែលបានលើកទឹកចិត្តកូនប្រុស/ស្រីរបស់ខ្លួនខិតខំធ្វើការសិក្សាអោយបានខ្លាំងក្លានារដូវស្លឹកឈើធ្លាក់ជាចុងក្រោយនេះ។ នេះជារបៀបកែប្រែជីវិតខ្លួនអោយមានសារៈសំខាន់ដែលសាលារៀនបានណែនាំ។

ដោយក្តីរាក់ទាក់បំផុត

Carl A. Cohn
អគ្គស្នងការក្រសួងអប់រំប្រចាំក្រុង



BECOMING AMERICA'S BEST